ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
លេខាធិការដ្ឋាន
លេខ៖ ................................../គ.ជ.អ.ប.

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីការអនុម័តលើការផ្ដល់ហិរញ្ញប្បទានចំនួន ៩,៨ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់អនុវត្តគម្រោង រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (LGCC-3) ដើម្បីលើកស្ទួយសកម្មភាពអាកាសធាតុដែលអនុវត្តនៅមូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ទីក្រុងសុងដូ សាធារណរដ្ឋកូរ៉េខាងត្បូង ៖ ថ្ងៃព្រហស្បតិ៍ ៩កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ក្នុងអំឡុងពេលនៃកិច្ចប្រជុំលើកទី៤៣ របស់ក្រុមប្រឹក្សាមូលនិធិអាកាសធាតុបៃតង (GCF) គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (LGCC-3) ត្រូវបានអនុម័តជាផ្លូវការសម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងនេះ មានថវិកាសរុបចំនួន ៩,៨ លានដុល្លារអាមេរិក ដែលផ្ដល់ដោយមូលនិធិអាកាសធាតុបៃតង និងត្រូវដឹកនាំអនុវត្តដោយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។

ទស្សនវិស័យគម្រោងនេះដើម្បីបញ្ជ្រាបការឆ្លើយតបការទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យសំខាន់ៗដូចជា កសិកម្ម សុខាភិបាល ទឹក និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីការពារសហគមន៍ដែលងាយរងគ្រោះបំផុតនៅកម្ពុជា។ LGCC-3 នឹងជួយគាំទ្របច្ចេកទេស ធនធាន និងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបញ្ជ្រាបការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុក្នុងដំណើរការកសាងផែនការ និងថវិកាសម្រាប់វិនិយោគស្របលើសកម្មភាពបន្សាំដែលលើកឡើងដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅសហគមន៍មូលដ្ឋាន។

ចាប់តាំងឆ្នាំ ២០១១ ដោយមានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍សហប្រជាជាតិ (UNCDF) នៃកម្មវិធីការលើកកម្ពស់ការកែលម្អរជីវភាពមូលដ្ឋានបន្សាំទៅនឹងអាកាសធាតុ (LoCAL) នៅកម្ពុជា លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំអនុវត្ត និងដឹកនាំអនុវត្តគម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ (LGCC)។ នៅដំណាក់កាលដំបូង គម្រោង LGCC បានអនុវត្តក្នុងស្រុកចំនួន៣ នៅក្នុងខេត្តតាកែវ ដោយទទួលបានថវិកាជំនួយបន្ថែមពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអ៊ែត រួមជាមួយ UNCDF ផងដែរ។ ក្នុងដំណាក់កាលទី២ រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៥ បន្ថែមទៀតត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលផ្សារភ្ជាប់ ពីឆ្នាំ ២០១៦ - ២០១៩ រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៨ នៅក្នុខេត្តតាកែវ និងបាត់ដំបងក៏ទទួលបាននូវការគាំទ្រទៀតបន្ថែមផងដែរ។


លេខាធិការដ្ឋាននៃគ.ជ.អ.ប.៖ ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ អគារ (V) មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
National Committee for Sub-National Democratic Development Secretariat (NCDDS): Located in Ministry of Interior (Building V) Norodom Bvl., Tonle Bassac Sangkat, Chamkarmon Khan, Phnom Penh Kingdom of Cambodia Email: info@ncdd.gov.kh Website: www.ncdd.gov.kh

គោលបំណងសំខាន់ LGCC-3 គឺបង្កើនសមត្ថភាពធន់នឹងអាកាសធាតុរបស់សហគមន៍ នៅក្នុងរដ្ឋបាលស្រុកចំនួន ២៥ នៃប្រទេសកម្ពុជា។ ការអនុវត្តនេះ នឹងបង្កើនសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន និងសហគមន៍ អាចប្រើប្រាស់ និងគៀរគរថវិកាសម្រាប់លើកកម្ពស់ការរៀបចំផែនការវិនិយោគ និងអន្តរាគមន៍នានា ប្រកបដោយប្រសិទ្ធភាពសម្រាប់ការបន្សាំនឹងអាកាសធាតុ ដើម្បីរួមចំណែកសម្រេចគោលដៅអាកាសធាតុថ្នាក់ជាតិ វិស័យអាទិភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ ដោយដំណាក់កាលទី១ គឺពីរឆ្នាំដំបូងនឹងផ្តោតលើស្រុកចំនួន១៥ នៅខេត្តបាត់ដំបង ព្រះវិហារ និងពោធិ៍សាត់ បន្ទាប់មកក្នុងដំណាក់កាលទី២ គឺចាប់ពីឆ្នាំទី៣ នឹងបន្ថែមស្រុកចំនួន១០បន្ថែមទៀត។ ជារួមគម្រោងនេះនឹងឈានទៅគ្របដណ្តប់ស្រុកចំនួន២៥ ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ ដូចដែលបានកំណត់ក្នុងសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបានរបស់គម្រោង។

ស្រុកគោលដៅដែលបានជ្រើសរើសទាំងនោះ កំពុងប្រឈមនឹងហានិភ័យ ពីការកើនឡើងនៃទឹកជំនន់ គ្រោះរាំងស្ងួត ប្រជាពលរដ្ឋក៏ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅ សុខភាពផងដែរ។ នាពេលបច្ចុប្បន្នរដ្ឋបាលស្រុកជាច្រើនទៀត នៅពុំទាន់មានការយល់ដឹង និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីវាយតម្លៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ ឬលើកជាវិធានបន្សាំខ្លួនទៅការប្រែប្រួលអាកាសធាតុចូលក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល ដែលឆ្លើយតបទៅតម្រូវការប្រកបដោយប្រសិទ្ធភាពនៃក្រុមជនងាយរងគ្រោះដូចជា ស្ត្រី ជនជាតិដើមភាគតិច ជនមានពិការភាព ជនចាស់ជរា កុមារ និងជនក្រីក្រ។ ឈានចូលដំណាក់កាលទី៣ នេះ LGCC-3 នឹងពង្រីកការគាំទ្រទៅដល់កម្រិតក្រុងស្រុក ចំនួន២៥។

**ឯកឧត្តម ឆេង ទឡ្ហេ:** អនុប្រធាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. បានមានប្រសាសន៍គូសបញ្ជាក់ថា ៖ ថវិកាដែលទទួលបានពីមូលនិធិអាកាសធាតុបៃតង (GCF) តាមរយៈគម្រោង LGCC-3 គឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីជាច្រកឱ្យមានហិរញ្ញប្បទានសម្រាប់ការកសាងសមត្ថភាព ជំនួយបច្ចេកទេស និងវិនិយោគក្នុងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋានដើម្បីធ្វើឱ្យមានការវិវឌ្ឍន៍ដ៏ល្អប្រសើរក្នុងការកសាងនូវភាពធន់នឹងអាកាសធាតុ។ ត្បិត កម្ពុជាកំពុងវិវត្តន៍ខ្លួនចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចក៏ពិតមែន ប៉ុន្តែនៅមានបណ្តាខេត្តនានាដែលនៅតែបន្តជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន តួយ៉ាងដូចជាភាពក្រីក្រ និងភាពងាយរងគ្រោះ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

**លោក** HEMANT Mandal ប្រធាននាយកដ្ឋានប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក មូលនិធិអាកាសធាតុបៃតង បានបន្ថែមថា៖ "គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣នេះ ជាគម្រោងដំបូងបង្អស់របស់ គ.ជ.អ.ប. ដែលទទួលបានឱកាសបង្ហាញពីការប្តេជ្ញាចិត្តក្នុងកិច្ចប្រជុំលើកទី៤៣ របស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិអាកាសធាតុបៃតង ក្នុងការទទួលយកគម្រោងមកអនុវត្ត ដើម្បីពង្រឹងភាពជាម្ចាស់ និងជំរុញលើកកម្ពស់ផែនការបន្សាំ ដោយដឹកនាំ និងអនុវត្តផ្ទាល់នៅថ្នាក់មូលដ្ឋាន ក្នុងការធានាដល់ការបង្កើនភាពធន់នឹងអាកាសធាតុ ក្នុងវិស័យកសិកម្ម ទឹក សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញឱ្យកម្ពុជា ឈានឆ្ពោះរកភាពធន់ បរិយាបន្ន ចីរភាពទៅអនាគតសម្រាប់

ទាំងអស់គ្នា។ ទន្ទឹមនេះ LGCC-3 នឹងគាំទ្រដល់ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការធ្វើផែនការបង្ការហានិភ័យទុកជាមុន ការអនុវត្ត និងតាមដានការវិនិយោគដែលអាចបន្សាំនឹងអាកាសធាតុនៅមូលដ្ឋាន រួមទាំងការបញ្ចូលជាប្រព័ន្ធ ដល់ការសម្របសម្រួលការវាយតម្លៃមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត (PBCRG) ដោយចូលរួមអនុវត្តយន្តការបែងចែកហិរញ្ញប្បទានអាកាសធាតុពីថ្នាក់ជាតិទៅដល់ថ្នាក់ក្រោមជាតិ។

សរុបជារួម LGCC-3 នឹងត្រួសត្រាយផ្លូវសម្រាប់បញ្ចូលជាប្រព័ន្ធនៃភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីបង្កើនការវិនិយោគដែលសមស្របទៅនឹងអាកាសធាតុនៅរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃសុក្រ ២រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥